ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំទទុង-ភ្នំតូច

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សម្រេច

មាត្រា១ ._

ត្រូវបានបង្កើតតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំទទុង-ភ្នំតូច ផ្ទៃដីទំហំ ៨៣,៤៤(ប៉ែតសិបបីហិចតា និងសែសិបបួនអា) ស្ថិតក្នុងស្រុកដងទង់ និងស្រុកបន្ទាយមាស ខេត្តកំពត ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកា(Datum:WGS1984) ដូចខាងក្រោម៖

និយាមកាគោល

ID	X	Y	ID	X	Y	ID	X	Y	ID	X	Y
1	447441	1183184	19	448135	1183024	37	447688	1182026	55	447602	1182708
2	447520	1183226	20	448126	1182996	38	447594	1182060	56	447573	1182723
3	447542	1183239	21	448123	1182957	39	447539	1182094	57	447505	1182741
4	447794	1183325	22	448108	1182927	40	447506	1182120	58	447445	1182739
5	447789	1183364	23	448083	1182910	41	447476	1182150	59	447428	1182772
6	447908	1183396	24	448055	1182901	42	447428	1182217	60	447372	1182792
7	447936	1183341	25	448054	1182857	43	447393	1182298	61	447325	1182822
8	447963	1183341	26	448070	1182801	44	447379	1182355	62	447281	1182856
9	448014	1183340	27	448081	1182761	45	447557	1182471	63	447258	1182890
10	448033	1183337	28	448087	1182721	46	447643	1182526	64	447245	1182918
11	448060	1183294	29	448105	1182639	47	447649	1182566	65	447254	1182945
12	448090	1183234	30	448119	1182555	48	447699	1182586	66	447280	1182985
13	448104	1183214	31	448130	1182514	49	447693	1182618	67	447309	1183028
14	448131	1183193	32	448164	1182509	50	447685	1182634	68	447279	1183038
15	448153	1183171	33	448169	1182350	51	447666	1182655	69	447290	1183089
16	448157	1183124	34	448102	1182187	52	447658	1182672	70	447341	1183086
17	448155	1183092	35	448001	1182087	53	447614	1182675			
18	448142	1183067	36	447854	1182025	54	447597	1182685			

មាត្រា២ ._

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ការពារតួនាទីផ្នែកប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាប្រយោជន៍របស់មនុស្សគ្រប់ជំនាន់
- កម្រិតដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារនៃតំបន់នេះ
- ការពារសោភ័ណភាព ទេសភាពធម្មជាតិ និងតម្លៃធម្មជាតិនៃតំបន់នេះសម្រាប់បម្រើដល់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្ករការគំរាមកំហែងដល់បរិស្ថាន ធម្មជាតិ និងវប្បធម៌នៅក្នុងមូលដ្ឋាន
- ផ្តល់សេវាកម្មធម្មជាតិ និងវប្បធម៌សម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់។

មាត្រា៣ ._

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ និងគ្រប់គ្រងតំបន់បេតិកភណ្ឌធម្មជាតិ ភ្នំព្រះគុហារហ្លួង ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តកំពត និងកងកម្លាំងប្រដាប់អាវុធមានសមត្ថកិច្ច ដើម្បីធានាដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិ នៃច្បាប់ជាធរមាន។

មាត្រា៤ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៥ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងវប្ផធម៌ និងវិចិត្រសិល្ប: រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមការកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩ កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ធកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី តំបន់បេតិកភណ្ឌធម្មជាតិ ភ្នំទទុច-ភ្នំតូច

ស្ថិតក្នុងភូមិសាស្ត្រ ស្រុកជ័យសិន និងស្រុកបន្ទាយមាស ខេត្តកំពត ផ្ទៃដីទំហំ ៨៣.៤៤ហិចតា

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ: ១៣ អនក្រ.បក ចុះថ្ងៃទី ២២ ខែ ១០ ឆ្នាំ២០២១



ប្រទេសកម្ពុជា

និយាមកាគោល

ID	X	Y	ID	X	Y	ID	X	Y
1	447441	1183184	24	448055	1182901	47	447649	1182586
2	447520	1183226	25	448054	1182857	48	447699	1182586
3	447542	1183239	26	448070	1182801	49	447693	1182618
4	447794	1183325	27	448081	1182761	50	447685	1182634
5	447789	1183364	28	448087	1182721	51	447666	1182655
6	447908	1183396	29	448105	1182639	52	447658	1182672
7	447936	1183341	30	448119	1182555	53	447614	1182675
8	447963	1183341	31	448130	1182514	54	447597	1182685
9	448014	1183340	32	448164	1182509	55	447602	1182708
10	448033	1183337	33	448169	1182350	56	447573	1182723
11	448060	1183294	34	448102	1182187	57	447505	1182741
12	448090	1183234	35	448001	1182087	58	447445	1182739
13	448104	1183214	36	447854	1182025	59	447428	1182772
14	448131	1183193	37	447688	1182026	60	447372	1182792
15	448153	1183171	38	447594	1182060	61	447325	1182822
16	448157	1183124	39	447539	1182094	62	447281	1182856
17	448155	1183092	40	447506	1182120	63	447258	1182890
18	448142	1183067	41	447476	1182150	64	447245	1182918
19	448135	1183024	42	447428	1182217	65	447254	1182945
20	448126	1182996	43	447393	1182298	66	447280	1182985
21	448123	1182957	44	447379	1182355	67	447309	1183028
22	448108	1182927	45	447557	1182471	68	447279	1183038
23	448083	1182910	46	447643	1182526	69	447290	1183089
						70	447341	1183086

សញ្ញាសម្គាល់

- ● ចំណុចនិយាមកា
- ——— ខ្សែរយៈកម្ពស់
- ▭ ព្រំប្រទល់តំបន់បេតិកភណ្ឌធម្មជាតិ

ប្រភពទិន្នន័យ:

ចំណុចនិយាមកា និងខ្សែព្រំប្រទល់: ក្រសួងបរិស្ថាន

ព្រំប្រទល់រង្គបាល: ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រូបភាព: Google Earth, Feb-2019

ផលិតដោយ: នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន